*Kampuchean Action for Primary Education*

# អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

ឯកសារយោង

# ការរៀបចំទឹកស្អាតនៅក្នុងសាលារៀន

( សេចក្តីព្រាង )

កំពង់ចាម , ខែ ៦ ២០០៣

ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា

# ការរៀបចំទឹកស្អាតនៅក្នុងសាលារៀន

## I. សេចក្តីផ្តើម :

ទឹកសម្រាប់បរិភោគ ដែលស្អាត គឺពិតជាមានសារៈសំខាន់ ជាពិសេសកុមារអាចគេចផុតពីជម្ងឺរាគរូស ឬ ឈឺពោះ ។ ឯកសារនេះ ផ្តល់ជំនួយដល់នាយកសាលា ព្រមទាំងគ្រូបង្រៀនដែលត្រូវការរៀបចំទឹកស្អាតផ្តល់ជូនសិស្ស ។ ដើម្បីណែនាំពីឯកសារនេះ សាលារៀនត្រូវមានអណ្តូងស្នប់ ឬ អណ្តូងដៃ ។ ប្រសិននៅសាលារៀនពុំទាន់មានអណ្តូងស្នប់ឬអណ្តូងទេ សាលាត្រូវរៀបចំ អណ្តូងស្នប់ ឬ អណ្តូង ជាមួយនឹងជំនួយរបស់សហគមន៍ ឬ ពីអង្គការអភិវឌ្ឍន៍ ដូចជា យូនីសេហ្វ Action against Hunger , Red Cross . . . ។ល ។

នាយកសាលា ត្រូវប្រាកដថា ទឹកដែលបានមកពីប្រភពទាំងនេះ ត្រូវតែមានគុណភាពខ្ពស់ ( ទឹកស្អាត ) ។ ចំពោះអង្គការណាមួយដែលបានផ្តល់នូវ អណ្តូង ឬ អណ្តូងស្នប់ គេអាចវិភាគទៅលើទឹក ដើម្បីធានាថាទឹកនោះពិតជាទឹកស្អាតមិនប៉ះពាល់ដល់សុខភាព ។

## II. គោលបំណង :

សិក្ខាកាម អាចរៀបចំការផ្តល់ទឹកស្អាត នៅក្នុងសាលា ដើម្បីជួយលើកស្ទួយសុខភាពរបស់កុមារ ។

## III. រយៈពេល :

ការរៀបចំការប្រជុំក្នុងសាលា ជាមួយគ្រូទាំងអស់ត្រូវចំណាយពេល កន្លះ ថ្ងៃ ។ បន្ទាប់ពីការប្រជុំនេះ យើងត្រូវរៀបចំប្រជុំបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍ស្តីអំពីមេរៀនដែលទាក់ទងទៅ នឹង ទឹកស្អាត ។

## IV. សម្ភារ :

- ក្រដាសរ៉ាម A ៤
- ហ្វឺតក្តារខៀន
- ក្តារខៀន ស ។

## V. លំនាំបង្រៀន :

1. នាយកសាលា ត្រូវរៀបចំការប្រជុំរួមជាមួយបុគ្គលិកក្នុងសាលាដោយជំរាបថា សាលារៀនចង់អោយសិស្សទាំងអស់ទទួលបាននូវការណែនាំអំពីទឹកស្អាត ។ នាយកសាលា ត្រូវសួរសំណួរដូចខាងក្រោមដើម្បីអោយគ្រូពិភាក្សាជាក្រុមតូច ÷

- បើសិនយើងមានទឹកស្អាតសម្រាប់ប្រើប្រាស់នៅក្នុងសាលា តើវាមានសារៈសំខាន់អ្វីខ្លះ ?

**ចម្លើយ** :

  - បើសិនកុមារមិនស្រេកទឹកទេ គេអាចរៀនបានប្រសើរ និង ជួយកាត់បន្ថយអវត្តមាន ពីព្រោះសិស្សដែលអវត្តមានភាគច្រើន គឺគេមានជំងឺរាគរូស ឈឺពោះ ។ល ។
  - សិស្សអាចចំណេញប្រាក់ ពីព្រោះឪពុកម្តាយមិនបាច់ចំណាយប្រាក់ដើម្បីទិញថ្នាំ ។

ប្រសិនបើចម្លើយរបស់គ្រូពុំបានបង្ហាញដូចគំនិតខាងលើទេ នាយកសាលា គប្បីប្រើសំណួរបំផុសដើម្បីប្រមូលយកគំនិតដូចខាងលើ ។

2. នាយកសាលា ត្រូវសួរសំណួរបន្តទៀត ដើម្បីអោយគ្រូពិភាក្សាជាក្រុមតូច :

- តើយើងអាចរៀបចំទឹកស្អាតយ៉ាងដូចម្តេចនៅក្នុងថ្នាក់រៀនរបស់យើង ?

**ចម្លើយ** :

- បែងចែកសិស្សអោយដងទឹកពីអណ្តូងស្នប់ ដាក់ក្នុងថ្នាក់រៀនអោយបានរាល់ថ្ងៃសម្រាប់លាងសំអាតដៃ
- រៀបចំកន្លែងនៅក្នុងថ្នាក់រៀនសម្រាប់ទុកទឹកស្អាត
- ត្រូវប្រាកដថា កែវ/កាទឹក សម្រាប់ដួសទឹក ត្រូវតែសំអាតអោយបានស្អាតបន្ទាប់ពីប្រើរួច
- ផ្តល់សម្ភារសម្រាប់រៀបចំទឹកស្អាត ដូចជា ធុងទឹក នឹង កែវ/កាទឹក
- ត្រូវផ្តាប់កែវ/ពែង និង គ្របធុងទឹក អោយជិតដើម្បីការពារធូលី វត្ថុ/សត្វផ្សេង ៗ ចូលក្នុងនោះ ។

នាយកសាលា ត្រូវកត់ត្រាចម្លើយលើក្តារខៀន ។ ប្រសិនប្រើចម្លើយរបស់គ្រូ ពុំបានបង្ហាញដូចខាងលើទេ នាយកសាលា ត្រូវប្រើសំណួរបំផុសដើម្បីប្រមូលគំនិតទាំងនេះ ។

3. នាយកសាលា គប្បីពន្យល់ថា ចំណុចដែលបានសរសេរលើក្តារខៀនគឺជាគំនិតមួយដើម្បីយកគំនិតទាំងនេះទៅពិចារណាក្នុងការរៀបចំទឹកស្អាតនៅក្នុងថ្នាក់រៀន ។ ដើម្បីរៀបចំ គ្រូគួរតែ ÷

- កំណត់ពេលវេលា ដើម្បីបង្រៀនសិស្សអំពីការប្រើប្រាស់ទឹកស្អាត
- ត្រួតពិនិត្យតាមដាន និង អនុវត្តការរៀបចំប្រើប្រាស់ទឹកស្អាតនៅក្នុងបន្ទប់រៀន ។

នាយកសាលាត្រូវធ្វើការស្នើសុំនូវរបៀបបង្រៀនកុមារអោយបានយល់ដឹងពីទឹកស្អាត ។ ពតិមានដែលទាក់ទងនឹងទឹកស្អាត ក្នុងការប្រើប្រាស់អណ្តូងស្នប់ របៀបទុកដាក់ទឹកស្អាត រក្សាប្រភពទឹកអោយបានស្អាត ដែលមាននៅក្នុងកម្មវិធីសិក្សា ។

ការប្រជុំបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍ ត្រូវតែកំណត់នូវប្រធានបទផ្សេង ៗ ក្នុងកម្មវិធីសិក្សាដែលទាក់ទងនឹងទឹកស្អាត ។ បន្ទាប់មកគ្រូ ត្រូវកំណត់ពេលវេលាអោយបានសមស្របដើម្បីបង្រៀនមេរៀននេះ ។ ដើម្បីអោយមេរៀននេះមានលក្ខណៈដូចកុមារមេត្រី ។ យើងអាចបញ្ចូលសកម្មភាពមួយចំនួនដូចខាងក្រោម ÷

- **គូររូបភាព** : សិស្សថ្នាក់ទី ១ , ២ ,៣ និង ថ្នាក់ទី ៤ អាចគូររូបភាពដែលពាក់ព័ន្ធទៅនឹងប្រធានបទជាក់ស្តែងអំពីទឹកស្អាត ។ ចំពោះសិស្ស ថ្នាក់ទី ៥ និង ថ្នាក់ទី ៦ អាចធ្វើផ្ទាំងរូបភាពដែលបង្ហាញពីពតិមានសុខភាពអនាម័យដែលទាក់ទងនឹងប្រធានបទដូចគ្នា ។ ផ្ទាំងរូបភាពនេះ ត្រូវដាក់បង្ហាញក្នុងសាលា ឬ នៅក្នុងសហគមន៍ (ដោយប្រើក្តារខៀនរបស់សហគមន៍ ) ។
- **ល្ខោនត្រាប់** : ល្ខោនត្រាប់ គឺជាសកម្មភាពមួយដែលមនុស្សម្នាក់ព្យាយាមធ្វើកាយវិការ ឬ បង្ហាញតាមរយៈទឹកមុខដោយមិននិយាយ ហើយអ្នកផ្សេងទៀតអាចទស្សន៍ទាយ ឬ សន្និដ្ឋានថាជាអ្វី ? សិស្សអាចធ្វើល្ខោនត្រាប់ដោយទាក់ទងនឹងទឹកស្អាត (ដងទឹកចេញពីអណ្តូង ) គ្របគម្របធុងទឹក , ទឹកដែលអាចហូបបាន ។ ល ។ បន្ទាប់មកសួរសិស្សផ្សេងទៀតដើម្បីឆ្លើយអំពីខ្លឹមសាររបស់ល្ខោនត្រាប់ ។
- **ការសម្តែងតួ** : គ្រូអាចរៀបចំការសម្តែងតួ ដោយផ្តោតទៅលើប្រធានបទទឹកស្អាត ។
- **សកម្មភាពស្រាវជ្រាវ** : សិស្សអាចធ្វើការស្រាវជ្រាវនៅផ្ទះ ឬ នៅសាលាអំពីទឹកស្អាត ។ ជាឧទាហរណ៍ : សិស្សអាចគណនាបរិមាណទឹកដែលប្រើប្រាស់នៅផ្ទះ ឬ នៅក្នុងសាលាក្នុងរយៈពេល ១ សប្តាហ៍ ។

**4.** នាយកសាលា បន្តពន្យល់ទៀតថា ពិតជាមានសារៈសំខាន់ណាស់ ដែលគ្រូត្រូវបន្តការត្រួតពិនិត្យការរៀបចំទៅលើការប្រើប្រាស់ទឹកស្អាត ។

នាយកសាលា ត្រូវបិទការប្រជុំដោយរំលឹកឡើងវិញថា ការផ្តល់នូវទឹកស្អាត គឺជាកត្តាចង្អុលបង្ហាញមួយនៅក្នុងឧបករណ៍វាយតំលៃសាលាកុមារមេត្រី ។ នាយកសាលា ត្រូវបញ្ជាក់ប្រាប់គ្រូទាំងអស់ត្រូវព្យាយាមអោយអស់ពីសមត្ថភាពដើម្បីធានាថា សាលានឹងទទួលបាននិទ្ទេសល្អនៅក្នុងឧបករណ៍វាយតម្លៃ ។

**ចំណាំ** :

- ចំពោះសាលាដែលបានបង្កើតសមាគមសិស្ស គេអាចជួយគ្រូដើម្បីអនុវត្តទៅលើសកម្មភាពនេះ ។
- មានមេរៀនមួយស្តីអំពីទឹកស្អាតនៅក្នុងសៀវភៅគ្រូរបស់ អង្គការ យូនីសេហ្វ និង ក្រសួងអប់រំយុវជន និង កីឡា ( បោះពុម្ពឆ្នាំ ២០០២ ទំព័រទី ៧៩ ដល់ ១០៤ ) សៀវភៅនេះអាចរកទិញតាមរយៈអង្គការ យូនីសេហ្វ ( ក្រុមការងារតាមខេត្ត ) ឬ ខេប ។